## ៦. ផែនការគ្រប់គ្រងបរិស្ថាន តម្រូវការស្ថាប័ន និងការពិនិត្យ-តាមដាន-វាយតំលៃបរិស្ថាន

១៨៣. យោងលើការិតនៃផលប៉ះពាល់បង្កឡើងដោយសកម្មភាពអភិវឌ្ឍន៍ បង្ហាញថា គំរោងនេះមិនតម្រូវឱ្យមានការចូលរួមពីស្ថាប័ន និងការត្រួតពិនិត្យបរិស្ថានច្រើនប៉ុន្មានទេ ដោយសារថា ហេតុប៉ះពាល់អវិជ្ជមានមានតិចតួច។ ក្រៅពីអ្នកសម្របសម្រួលបរិស្ថានរបស់ក្រុមហ៊ុន (Local Environmental Coordinator) និងស្ថាប័នជំនាញ (មានក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) គម្រោងនេះមិនចាំបាច់តម្រូវឱ្យមានស្ថាប័នត្រួតពិនិត្យឯករាជ្យ (Independent Monitoring Organization) ដើម្បីត្រួតពិនិត្យការអនុវត្តន៍ទេ។ ប៉ុន្តែក្រុមហ៊ុន **បៀន ហៀក អ៊ិនវេសមេន (BEAN HEACK INVESTMENT Co., Ltd.)** ខ្លួនឯងមានតួនាទីទទួលខុសត្រូវស្នូលក្នុងការគ្រប់គ្រងបរិស្ថានរបស់គំរោង ដោយផ្អែកលើវិធានការណ៍គ្រប់គ្រងបរិស្ថាន ដូចបានកំណត់នៅក្នុងផែនការគ្រប់គ្រងបរិស្ថាន របស់របាយការណ៍ ESIA។ ក្នុងបរិបទនេះ ដើម្បីធានាបានថា **បៀន ហៀក អ៊ិនវេសមេន** ប្រតិបត្តិតាមវិធានការណ៍ នៃការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន និងសង្គម ដូចកំណត់នៅក្នុងតារាងទី ៦-១ និង៦-៣ បានត្រឹមត្រូវនោះ ក្រសួងបរិស្ថាន (នាយកដ្ឋាន EIA) និងក្រុមការងារចំរុះរបស់លេខាធិការដ្ឋានបច្ចេកទេសត្រូវចុះពិនិត្យ និងវាយតំលៃដំណើរប្រតិបត្តិរបស់ក្រុមហ៊ុនទៅតាមកម្មវិធីដូចមានកំណត់នៅក្នុងតារាង ៦-៣ ដោយផ្ទាល់។

## តារាង ៦-១: វិធានការសង្ខេបកាត់បន្ថយហេតុប៉ះពាល់

| សកម្មភាពគំរោង | សក្តានុពល ហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តម្លៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ផលប៉ះពាល់មុនពេលប្រតិបត្តិគំរោង – ក្នុងដំណាក់កាលរៀបចំគំរោង** | | | | |
| **ការរៀបចំគំរោង** | **រៀបចំគំរោងមិនបានត្រឹមត្រូវ (ប្រសិនបើ)** | • ក្រុមហ៊ុន **បៀន ហៀក អ៊ិនវេសមេន** បានប្រើទស្សនៈនៃការអភិវឌ្ឍន៍ លក្ខណៈ ជាប្រព័ន្ធក្នុងការរៀបចំគំរោង ដោយមានការបែងចែកការប្រើប្រាស់ដីសំខាន់ៗពីរប្រភេទ គឺ :<br>១. ដីប្រើប្រាស់: ដីសម្រាប់ដាំកៅស៊ូ និងដីសម្រាប់រៀបចំប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ។<br>២. ដីដែលមិនអាចប្រើប្រាស់បាន: ដីស្រែចំការរបស់ប្រជាពលរដ្ឋមូលដ្ឋាន និងដីតំបន់ទ្រនាប់ប្រព័ន្ធផ្លូវទឹក<br>• ផលធៀបរវាងដីប្រើប្រាស់ និងដីដែលមិនអាចប្រើប្រាស់បាន មានចំនួន២២,៧៨ដង ឬមានន័យថា ដីដែលមិនអាចប្រើប្រាស់មានចំនួន ៤,៥៩ភាគរយនៃដីប្រើប្រាស់ ។ | ក្រុមហ៊ុន **បៀន ហៀក អ៊ិនវេសមេន** | ១២០.០០០ |

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តម្លៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ផលប៉ះពាល់មុនពេលប្រតិបត្តិគំរោង – ក្នុងដំណាក់កាលរៀបចំគំរោង** | | | | |
| ការធ្វើផែនការ | សុខភាពការងារ និងផែនការសុវត្ថិភាព | (១) **ការការពារជំងឺគ្រុនចាញ់:** ប្រសិនបើគ្មានការគ្រប់គ្រងកន្លែងដែលមូសរស់នៅឱ្យបានជិតដល់ទេ អាចនឹងធ្វើឱ្យកើតជំងឺគ្រុនចាញ់បាន។ អនុសាសន៍សំខាន់ៗសំរាប់ការការពារនិងការកាត់បន្ថយនូវការកើតជំងឺមានដូចជា: (១) ការស្វែងរកឱ្យបានទាន់ពេលវេលាតាមរយៈការពិនិត្យលើលក្ខណៈគ្លីនិកចំពោះអ្នកផ្ទុកជំងឺដែលមានលក្ខណៈខ្ពស់ (២) ផ្តល់ការព្យាបាលឱ្យបានត្រឹមត្រូវ និងគ្រប់គ្រាន់នៅគ្រប់ករណីនៃការកើតមានទាំងអស់ (៣) ធ្វើរបាយការណ៍អំពីការកើតមាននិងតាមដានអ្នកដែលប៉ះពាល់ឬនៅជាមួយនឹងអ្នកជំងឺ (៤) ផ្តល់ការណែនាំអំពីការប្រើថ្នាំការពារជំងឺគ្រុនចាញ់ឱ្យបានត្រឹមត្រូវ (៥) ជ្រលក់មុងជាមួយនឹងរបាយ Pyrathroid (៦) អនុវត្តន៍គំរោងកែលំអអនាម័យ ដើម្បីបំបាត់កន្លែងរស់នៅរបស់មូស និងផ្តល់ការអប់រំអំពីបញ្ហាសុខភាព និងការការពារជំងឺគ្រុនចាញ់ (៧) ដាក់សំណាញ់តាមទ្វារ និងបង្អួចផ្ទះ (៨) ប្រើមុងជាប្រចាំ (៩) ស្លៀកពាក់ខោអាវដៃវែងនិងប្រើថ្នាំការពារមូស (១០) តាមដានគ្លីនិកនិងរោគសញ្ញារបស់ជំងឺ (១១) ធ្វើរោគវិនិច្ឆ័យនិងផ្តល់ការព្យាបាលឱ្យបានទាន់វេលា និង (១២) ត្រួតពិនិត្យនូវឧប្បត្តិហេតុ និងកំណត់ទីកន្លែងកើតមានជំងឺ។<br>(២) **ការគ្រប់គ្រងការរាគត្បាត:** វិធានការគ្រប់គ្រងការរាគត្បាតមាន (១) បំបែកអ្នកជំងឺឱ្យនៅផ្សេង និងព្យាបាលទៅតាមប្រភេទជំងឺ (២) បាញ់ថ្នាំក្នុងបរិវេណរស់នៅ២០០ម៉ែត្រ ដើម្បីសម្លាប់មូសដែលពេញវ័យ (៣) ស្វែងរក និងបំផ្លាញជំរកមូស (៤) ប្រើប្រាស់ថ្នាំសំលាប់ពងមូសតាមកន្លែងមានមូសច្រើន និង (៥) អប់រំបុគ្គលិកកម្មករ និងសហគមន៍អំពីវិធានការគ្រប់គ្រងការរាគត្បាត។ | ក្រុមហ៊ុន **បៀន ហៀក អ៊ិនវេសមេន** | ដកពីខ្ទង់ចំណាយផ្សេងៗ និងប្រាក់ធានារ៉ាប់រងសង្គម ដែលមានទឹកប្រាក់សរុបប្រមាណ ២៦០.០០០ដុល្លា ក្នុងមួយឆ្នាំ (ផែនការមេ) |

Draft

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តម្លៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ផលប៉ះពាល់មុនពេលប្រតិបត្តិគំរោង (ត)** | | | | |
| ការធ្វើផែនការ | សុខភាពការងារ និងផែនការសុវត្ថិភាព | (៣) **ការការពារជំងឺដែលបង្កឡើងដោយការប្រើប្រាស់ទឹកមិនស្អាតៈ** ការកើតជំងឺគ្រុនពោះវៀន រាគមួល អាសន្នរោគ រលាកថ្លើម និងទឹកស៊ុំជើងមានកំរិតខ្ពស់ ដោយសារការខ្វះអនាម័យ ការប្រើប្រាស់បង្គន់សាធារណៈមានកំរិតទាប ការផ្គត់ផ្គង់ទឹកស្អាតនៅមានកំរិត និងការខ្វះអនាម័យរបស់កម្មករ។ អនុសាសន៍មួយចំនួនដែលអនុវត្តសម្រាប់ការពារនូវការកើតនូវជំងឺខាងលើមានៈ (ក) ក្រុមហ៊ុនត្រូវផ្តល់ទឹកស្អាតដល់កម្មករ (ខ) ត្រួតពិនិត្យជាប្រចាំអំពីគុណភាពរបស់ទឹក (វត្តមានរបស់បាក់តេរី សារធាតុគីមី និងពណ៌របស់ទឹក) (គ) ត្រូវធ្វើរោគវិនិច្ឆ័យ និងផ្តល់ការព្យាបាលឱ្យបានគ្រប់គ្រាន់និងទាន់ពេលវេលា (ឃ) តាមដានរកប្រភពចំលងនិងផ្តល់ការព្យាបាល (ង) ធានាឱ្យបាននូវសុវត្ថិភាព និងអនាម័យកាកសំណល់ និងការបោះចោលនូវកាកសំណល់រឹងនៅក្នុងផ្ទះដែលសង់សំរាប់កម្មករ (ច) កែលំអការសម្អាតបរិស្ថាននៅក្នុងបរិវេណទីស្នាក់ការ និងទីកន្លែងរស់នៅ ដោយការសង់បង្គន់អនាម័យ និងកន្លែងចោលកាកសំណល់រឹង (ឆ) កែលំអអនាម័យបុគ្គល ជាពិសេសចំពោះអ្នករៀបចំអាហារ (ជ) ផ្តល់វ៉ាក់សាំងចំពោះបុគ្គលិក ឬកម្មករបរទេសដែលពុំមានអង់ទីករប្រឆាំងជំងឺគ្រុនពោះវៀន អាសន្នរោគ និងរលាកថ្លើម និង (ឈ) រាយការណ៍និងធ្វើការត្រួតពិនិត្យអំពីឧប្បត្តិហេតុរបស់ជំងឺ។ | ក្រុមហ៊ុន **យៀន ហៀក អ៊ិនវេសមេន** | ដកពីខ្ទង់ចំណាយផ្សេងៗ និងប្រាក់ធានារ៉ាប់រងសង្គម ដែលមានទឹកប្រាក់សរុបប្រមាណ ២៦០.០០០ដុល្លា ក្នុងមួយឆ្នាំ (ផែនការមេ) |

Draft

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តម្លៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ផលប៉ះពាល់មុនពេលប្រតិបត្តិគំរោង (ត)** | | | | |
| ការធ្វើផែនការ | សុខភាពការងារ និងផែនការសុវត្ថិភាព | (៤) **ការការពារជំងឺផ្លូវភេទ:** ការការពារជំងឺផ្លូវភេទចំពោះកម្មករ និងសហគមន៍មូលដ្ឋាន អាចធ្វើបានតាមរយៈ (ក) អប់រំបុគ្គលិកកម្មករអំពីគ្រោះថ្នាក់នៃការឆ្លងជំងឺអេដស៍ និងជំងឺផ្លូវភេទផ្សេងៗទៀតដូចជា: ការទប់ស្កាត់នូវទំនាក់ទំនងជាមួយអ្នកដែលធ្វើអាជីវកម្មផ្លូវភេទការប្រើប្រាស់ស្រោមអនាម័យ ណែនាំអ្នកជំងឺឱ្យព្យាបាលជាមួយនឹងគ្រូពេទ្យដែលមានបទពិសោធន៍ និងមិនត្រូវព្យាបាលដោយខ្លួនឯង និង (ខ) រាយការណ៍អំពីអ្នកជំងឺ ស្វែងរកអ្នកចម្លង និងត្រួតពិនិត្យករណីនៃការកើតមានរបស់ជំងឺ ដោយការិយាល័យសុខាភិបាលនៅក្នុងតំបន់។ ប្រសិទ្ធិភាពនៃកម្មវិធីការពារជំងឺផ្លូវភេទទាមទារឱ្យមានកិច្ចសហប្រតិបត្តិការវវាង អាជ្ញាសុខាភិបាល អាជ្ញាធរ និងសហគមន៍មូលដ្ឋាន និងក្រុមហ៊ុន។<br>(៥) **ការរៀបចំផ្ទះ និងសុខភាព:** ការរៀបចំផ្ទះមិនបានត្រឹមត្រូវ អាចនាំឱ្យមានការចម្លងប៉ារ៉ាស៊ីតជំងឺចំលងតាមខ្យល់ គ្រោះថ្នាក់ដោយការប៉ះទង្គិច និងស្ត្រេសជាដើម។ តែបញ្ហាទាំងនេះអាចកាត់បន្ថយតាមរយៈការអនុវត្តនីវិធានការមួយចំនួនដូចជា: (ក) ត្រូវរៀបចំប្លង់កសាងទីស្នាក់ស្នូលឱ្យបានត្រឹមត្រូវ (ខ) ត្រូវផ្តល់ផ្ទះដល់កម្មករទៅតាមល័ក្ខខ័ណ្ឌ: (គ) ទីតាំងផ្ទះចាំបាច់ត្រូវស្ថិតនៅផុតពីកំពស់ទឹកជំនន់ ស្ថិតនៅឆ្ងាយពីទីកន្លែងដែលអាចផ្តល់ភាពកខ្វក់ និងកន្លែងដែលមានសត្វល្អិតច្រើន។ ផ្ទះត្រូវមានសំណាញ់ការពារមូស មានពន្លឺ និងចរន្តខ្យល់គ្រប់គ្រាន់ (ឃ) លក្ខណៈអនាម័យ: ផ្តល់ទឹកស្អាតឱ្យបានគ្រប់គ្រាន់ជាមួយនឹងមធ្យោបាយសំរាប់ដុសលាងនិងងូតទឹក សង់បង្គន់អនាម័យ និងកន្លែងសំរាប់ចោលកាកសំណល់រឹងត្រឹមត្រូវ និង (ង) ពិនិត្យអំពីលទ្ធភាពនៃការផ្តល់កន្លែងសំរាប់លំហែ (តារាងបាល់បោះ បាល់ទះ និងបាល់ទាត់) និងមណ្ឌលសុខភាព។ | ក្រុមហ៊ុន **ហៀន ហៀក អ៊ិនវេសមេន** | ដកពីខ្ទង់ចំណាយផ្សេងៗ និងប្រាក់ធានារ៉ាប់រងសង្គម ដែលមានទឹកប្រាក់សរុបប្រមាណ ២៦០.០០០ដុល្លា ក្នុងមួយឆ្នាំ (ផែនការមេ) |
| | ហានិភ័យសុវត្ថិភាព | • ការរៀបចំផែនការសុខភាព និងសុវត្ថិភាពការងារ ការផ្តល់នូវការបណ្តុះបណ្តាលផ្សេងៗ និងការណែនាំដល់បុគ្គលិកកម្មករទាំងមុនពេលប្រគល់ភារកិច្ចផ្សេងៗ។ | **ហៀន ហៀក អ៊ិនវេសមេន** | - |

Draft

| សកម្មភាពគំរោង | សក្តានុពល ហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | ការទទួល ខុសត្រូវរបស់ស្ថាប័ន | តម្លៃប៉ាន់ស្មាន |
|---|---|---|---|---|
| **មុនពេលប្រតិបត្តិគំរោង (ត)** | | | | |
| ការដោះស្រាយបញ្ហាកម្មសិទ្ធិដី | លំនាំនៃការផ្លាស់ប្តូរកម្មសិទ្ធិដី | • ការដោះស្រាយបញ្ហាកម្មសិទ្ធិដីត្រូវមានលក្ខណៈគតិយុត្តិ ដោយផ្អែកទៅលើលទ្ធភាពបៃការប្រើប្រាស់ដី និងឬទិន្នផលដែលម្ចាស់ដីធ្លាប់ទទួលបានពីមុន។ | | |
| ការរៀបចំទីតាំងសំរាប់ចតគ្រឿងចក្រ | បង្កការកខ្វក់ដល់មជ្ឈដ្ឋានជុំវិញ ដោយការលើកដីរៀបចំទីតាំងចតគ្រឿងចក្រ | • ការលើកដីធ្វើជាទីតាំងសម្រាប់ចតគ្រឿងចក្រមានដូចជា ឡានដឹកដី ម៉ាស៊ីនកាយដី ម៉ាស៊ីនពង្រាបដី ម៉ាស៊ីនឈូសដី ម៉ាស៊ីនកិនបង្ហាប់ដី ។ល។ គឺត្រូវការទំហំផ្ទៃដីប្រមាណ៦ហិកតា។ ការលើកដីនេះនឹងបង្កឱ្យកខ្វក់ដល់មជ្ឈដ្ឋានជុំវិញដូចជាៈ ការករជាកំណរល្បាប់ឬខ្សាច់នៅក្នុងតំបន់និងប្រភពទឹកដែលមាននៅជុំវិញនោះ។ តែហេតុប៉ះពាល់នេះមិនបង្កជាបញ្ហាធ្ងន់ធ្ងរដល់បរិស្ថានឡើយ ហើយអាចកាត់បន្ថយបានតាមៈ (១) ការដាំស្មៅនៅជុំវិញបរិវេណ (២) កិនបង្ហាប់ទីតាំងនោះឱ្យបានហាប់ល្អ និង (៣) ក្រាលគ្រួសក្រហមពីលើឱ្យបានកំរាស់ពី ១០-១៥ស.ម ហើយកិនបង្ហាប់ឱ្យ ល្អ។ | ក្រុមហ៊ុន **បៀន ហៀក អ៊ិនវេសមេន** | ១៥.០០០ |
| ទីតាំងរោងជាង និងកន្លែងស្តុកប្រេង | | • ប្រភពទឹកដែលមាននៅតាមទីកន្លែងស្តុកប្រេង ឃ្លាំងសម្ភារៈ កន្លែងសាងសង់ងាយនឹងទទួលរងនូវភាពកខ្វក់បំផុតដោយឧប្បត្តិហេតុធ្លុះធ្លាយឬការហូរចេញពីគ្រឿងចក្រ សំភារៈសំណង់ឬក៏ភាពកខ្វក់ដែលកើតឡើងដោយកំលាំងពលកម្ម ដែលអាចបង្កឱ្យកខ្វក់ដល់ដីនិងទឹក។ អាស្រ័យហេតុនេះប្រេងឥន្ទនៈ និងប្រេងរំអិលផ្សេងៗសំរាប់ការសាងសង់ និងសំភារៈគ្រោះថ្នាក់ដទៃទៀតចាំបាច់ត្រូវរក្សាឱ្យផុតពីកម្រិតកំពស់ទឹកជំនន់ ហើយនឹងមានចំងាយយ៉ាងតិច៣០-៥០ម៉ែត្រពីប្រភពទឹកដូចជាៈ ប្រព័ន្ធផ្លូវទឹក ប្រឡាយ និងស្រះទឹកជាដើម។ កន្លែងស្តុកប្រេងនិងរោងជាងត្រូវសង់ឱ្យខ្ពស់ជាងកំរិតកំពស់ទឹកជំនន់និងស្ថិតនៅក្នុងកន្លែងមួយដែលមានសុវត្ថិភាព ហើយការពារដោយអាងរក្សាប្រេងបិទជិតមួយដែលមានលទ្ធភាពគ្រប់គ្រាន់អាចស្តុកប្រេង ដែលហូរចេញពីកន្លែងស្តុកប្រេងបាន។ | ក្រុមហ៊ុន **បៀន ហៀក អ៊ិនវេសមេន** | ២០.០០០ |

Draft

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តម្លៃប៉ាន់ស្មាន |
|---|---|---|---|---|
| **មុនពេលប្រតិបត្តិគំរោង – ការសាងសង់ទីស្នាក់ការស្នូល និងប្រព័ន្ធផ្លូវនៅក្នុងតំបន់សម្បទាន** | | | | |
| ការឈូសសម្អាតរុក្ខជាតិចេញពីទីតាំងសាងសង់ទីស្នាក់ការស្នូល និង ប្រព័ន្ធផ្លូវនៅក្នុងតំបន់សម្បទាន | បង្កការកខ្វក់ដល់មជ្ឈដ្ឋានជុំវិញដោយការលើកដីរៀបចំទីតាំងចតគ្រឿងចក្រ | • ដើម្បីសាងសង់ទីស្នាក់ការស្នូល និងប្រព័ន្ធផ្លូវនៅក្នុងតំបន់សម្បទាន ក្រុមហ៊ុនត្រូវឈូសសម្អាតព្រៃចំនួន២៥៩ហិកតា។ ការឈូសសម្អាតនេះក៏អាចបណ្តាលឱ្យកខ្វក់ដល់មជ្ឈដ្ឋានជុំវិញដែរ តែដោយសារទីតាំងសាងសង់នោះធំ ហើយរុក្ខជាតិដែលមាននៅលើទីតាំងនោះមានមិនច្រើន ដូច្នេះ ហេតុប៉ះពាល់នេះគឺមិនធ្ងន់ធ្ងរទេ ហើយអាចកាត់បន្ថយបានតាមរយៈ (១) ឈូសរុក្ខជាតិដែលមាននៅទីនោះទៅគរទុកឱ្យមានសណ្តាប់ធ្នាប់ ពេលស្ងួតអាចដុតចោល ឬមួយក៏ចលនាឱ្យប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់នោះប្រមូលយកទុកប្រើប្រាស់ជាឧស (២) មិនត្រូវឈូសរុក្ខជាតិទាំងនោះទៅគរទុកលើប្រព័ន្ធផ្លូវទឹក (ប្រឡាយឬអូរ) ដែលអាចបង្កឱ្យមានការស្ទះដល់ចរន្តទឹកទេ និង (៣) រុក្ខជាតិធំៗ ត្រូវប្រើប្រាស់ទៅតាមលទ្ធភាពដែលអាចប្រើបាន។ | ក្រុមហ៊ុន **បៀន ហៀក អ៊ិនវេសមេន** | ៤៥០ដុល្លា/ហិកតា |
| | រំខានដល់មជ្ឈដ្ឋានជុំវិញ (សម្លេង រំញ័រ និងធូលី) | • ហេតុប៉ះពាល់បណ្តាលមកពីសម្លេង រំញ័រ និងធូលីបង្កដោយការធ្វើចរាចរណ៍របស់គ្រឿងចក្រនិងការបង្កឱ្យមានធូលី។ ហេតុប៉ះពាល់នេះមិនធ្ងន់ធ្ងរទេ ហើយអាចកាត់បន្ថយបានដោយការផ្តល់ដំណឹងអំពីកាលវិភាគការងារដល់សហគមន៍នៅក្នុងតំបន់នោះ។ បញ្ហាដែលបង្កចំពោះដំណុះរុក្ខជាតិនៅក្នុងតំបន់ អាចអូសបន្លាយរយៈពេល៦ខែរហូតដល់មានភ្លៀង។ ប៉ុន្តែហេតុប៉ះពាល់នេះអាចកាត់បន្ថយបានតាមរយៈការផ្សើមផ្លូវដោយការស្រោចទឹកជាប្រចាំ ហើយម្យ៉ាងទៀតនៅពេលមានភ្លៀងធ្លាក់ ទឹកភ្លៀងនឹងលាងជម្រះធូលីនោះចេញ ហើយរុក្ខជាតិនឹងដុះលូតលាស់ជាធម្មតាវិញ។ | ក្រុមហ៊ុន **បៀន ហៀក អ៊ិនវេសមេន** | ៦.០០០ដុល្លា/ឆ្នាំ |
| | ការច្រោះដី និងការជុះដី | • ការចាក់ឬលើកដីដើម្បីសាងសង់ទីស្នាក់ការស្នូល ឬប្រព័ន្ធផ្លូវនៅក្នុងតំបន់សម្បទាន ត្រូវផ្អាកនៅពេលមានភ្លៀងធ្លាក់ខ្លាំង ឬធ្វើត្រូវបញ្ចប់មុនពេលរដូវភ្លៀងធ្លាក់ខ្លាំង ដើម្បីជៀសវាងការរំខានឬហេតុប៉ះពាល់ដែលអាច កើតមានទៅលើដីធ្ងន់ធ្ងរ។ | ក្រុមហ៊ុន **បៀន ហៀក អ៊ិនវេសមេន** | - |

Draft

| សកម្មភាពគំរោង | សក្ដានុពល ហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវ របស់ស្ថាប័ន | តម្លៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ក្នុងពេលប្រតិបត្តិគំរោង – ការធ្វើផ្លូវនៅក្នុងតំបន់សម្បទាន** | | | | |
| ការធ្វើប្រព័ន្ធផ្លូវនៅក្នុងតំបន់សម្បទាន | ការច្រោះដី និងការជុះដី | • វិធានការណ៍មួយចំនួនដែលប្រើសម្រាប់កាត់បន្ថយហេតុប៉ះពាល់នៅក្នុងពេលធ្វើផ្លូវមាន:<br>✓ រក្សានូវមុំរបស់ផ្លូវ ទៅតាមផែនការវិស្វកម្មព្រៃឈើ ( មិនធំជាង១០ភាគរយចំពោះដីជ្រាយ និង មិនធំជាង១៨ភាគរយចំពោះដីរឹង)<br>✓ ជៀសវាងទីជំរាលវែង ដែលជាកន្លែងទឹកហូរចេញពីទ្រូងផ្លូវ ។ នៅកន្លែងដែលទីជំរាលវែង មិនអាចជៀសវាងបាន ត្រូវជីកចង្ហូរកាត់ទីជំរាល ចាក់ដីខ្សាច់ក្រាល និងជីកចង្ហូរនៅតាមដងផ្លូវ<br>✓ ត្រូវកាយចង្ហូរនៅតាមដងផ្លូវ ហើយទ្រូងផ្លូវត្រូវមានរាងជាខ្នងអណ្តើក ដើម្បីឱ្យងាយហូរធ្លាក់ទៅចង្ហូរ ។<br>✓ ជៀសវាងការដឹកធ្ងន់នៅក្នុងពេលកំពុងភ្លៀងឬនៅក្នុងសណ្ឋានភាពសើម<br>✓ ខ្នងផ្លូវត្រូវក្រាលថ្មបាយក្រៀមឬក៏កំទេចថ្ម<br>✓ ប្រើប្រាស់គ្រឿងចក្រឱ្យបានសមស្របដើម្បីកាត់បន្ថយហេតុប៉ះពាល់ពីការដាច់ដី<br>✓ ការពារតំបន់រណបរបស់អូរ និងស្ទឹង: រុក្ខជាតិដែលដុះនៅតាមដងស្ទឹងចាំបាច់ត្រូវរក្សាទុកទាំងស្រុងដើម្បីការពារផ្លូវទឹកនិងជីវិតនៅក្នុងទឹក ។ ពាក់ព័ន្ធនឹងបញ្ហានេះក្រុមហ៊ុនបានរក្សាទុកផ្ទៃដីសរុបចំនួន៣២០ហិកតា ដែលក្នុងនោះតំបន់ទ្រនាប់នៅអមបណ្តោយប្រព័ន្ធស្ទឹង និងតាមដៃសំខាន់នានា ។ នេះគឺជាវិធានការណ៍មួយដែលមានប្រសិទ្ធិភាពបំផុតក្នុងការកាត់បន្ថយហេតុប៉ះពាល់តាមប្រព័ន្ធប្រភពទឹក ។ | ក្រុមហ៊ុន **បឿន ហៀក អ៊ិនវេសមេន** | - |

Draft

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តម្លៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ក្នុងពេលប្រតិបត្តិគំរោង – ការឈូសសំអាតព្រៃដើម្បីដាំដំណាំកៅស៊ូ** | | | | |
| ការឈូសសំអាតព្រៃដើម្បីដាំដំណាំកៅស៊ូ | ការច្រោះដី និងការដុះដី | • វិធានការណ៍មួយចំនួនដែលប្រើសម្រាប់កាត់បន្ថយហេតុប៉ះពាល់ នៅក្នុងពេលឈូសសំអាតព្រៃដើម្បី ដាំដំណាំកសិ-ឧស្សាហកម្មមាន:<br>✓ ឈូសបើកគំរបព្រៃទៅតាមលទ្ធភាពនៃការដាំដុះនៅក្នុងឆ្នាំ ពោលគឺមិនត្រូវបន្សល់នូវផ្ទៃដីដែលឈូសហើសដោយមិនធ្វើការដាំដុះបានទេ ។<br>✓ កាកសំណល់ធំៗ របស់ឈើដែលកើតមាននៅក្នុងរយះពេលនៃការឈូស និងសំបកត្រូវកាត់ជាកំណាត់តូចៗ និងរាយនៅតាមដងផ្លូវ ប៉ុន្តែមិនត្រូវរុញឱ្យទៅគកស្ទះនឹងរុក្ខជាតិដែលនៅសេសសល់តាមដងផ្លូវឬក៏នៅកន្លែងទីជម្រាលនោះទេ ។ ពីព្រោះថា ក្រៅពីការការពារដី កាកសំណល់ទាំងនេះនិងពុកផុស និងផ្តល់ជីដល់ដីទៀតផង ។<br>✓ ផ្ទៃដីទំនេរស្ថិតនៅចន្លោះជួរដំណាំទាំងនោះ ចាំបាច់ត្រូវដាំដំណាំរួមផ្សំ (Intercrops) នៅក្នុងរយះពេល២-៣ឆ្នាំដំបូង រហូតដល់ពេលដើមឈើដាំទាំងនោះមានចុងមែកដុះស្ទើរជិត ។ | ក្រុមហ៊ុន **បឿន ហៀក អ៊ិនវែសមេន** | - |
| ប្រតិបត្តិការរៀបចំដី | ការច្រោះដី និងការដុះដី | • ការរៀបចំរណ្តៅលើផ្ទៃដីដែលឈូសហើយ មិនត្រូវប្រើវិធីភ្ជួរទេ ព្រោះការភ្ជួរនេះធ្វើឱ្យដីបែកខ្លាំងនេះនឹងបង្ករឱ្យការហូរច្រោះនឹងសិកដាច់មានកំរិតខ្ពស់ ។<br>• ការប្រើវិធីខួងដីធ្វើរណ្តៅដាំកូនឈើ អាចទប់ស្កាត់ការហូរច្រោះនឹងសឹកដាច់បានប្រសើរ ហើយការប្រើវិធីនេះធ្វើឱ្យអស់សោហ៊ុយតិចហើយលឿនទៀតផង ។ | ក្រុមហ៊ុន **បឿន ហៀក អ៊ិនវែសមេន** | - |
| ប្រតិបត្តិការដាំដុះ | ដាំមិនទាន់ធ្វើឱ្យដីសល់ទំនេរ | • កំណត់ពេលវេលាដាំដុះឱ្យបានត្រឹមត្រូវតាមរដូវកាលពោលគឺពីចន្លោះខែឧសភាទៅខែតុលា ។<br>• រៀបកម្លាំងការងារ (ទាំងមនុស្សនិងគ្រឿងចក្រ) ឱ្យបានត្រឹមត្រូវទៅតាម សមាមាត្រជាមួយនឹងទំហំការងារ ។<br>• មុននឹងចាប់ផ្តើមប្រតិបត្តិការ កម្លាំងពលករទាំងអស់ត្រូវបណ្តុះបណ្តាលឱ្យបានដិតដល់ដោយការសាកល្បងផ្ទាល់លើការងារ ( បទពិសោធន៍ សុខភាព សុវត្ថិភាព និងបញ្ហាបរិស្ថាន ។ | ក្រុមហ៊ុន **បឿន ហៀក អ៊ិនវែសមេន** | - |

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តម្លៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ក្នុងពេលប្រតិបត្តិគំរោង – ការឈូសសំអាតព្រៃដើម្បីដាំដំណាំកៅស៊ូ (ត)** | | | | |
| សម្លេង | ការរំខានដល់អារម្មណ៍ និងសោតវិញ្ញាណរបស់ពលករ | • កាត់បន្ថយល្បឿនរបស់គ្រឿងចក្រ<br>• ចៀសវាងការធ្វើការនៅពេលយប់<br>• កំណត់ពេលវេលានៃប្រតិបត្តិការទាំងឡាយណាដែលមានសំលេងខ្លាំង<br>• ពិនិត្យ និងតាមដានគ្រឿងចក្រឱ្យបានញឹកញាប់ និងដូរគ្រឿងបំលាស់ថ្មីចំពោះកន្លែងខូចខាតដែលជាមូលហេតុនាំឱ្យមានសំលេងខ្លាំងខុសប្រក្រតី<br>• ត្រូវភ្ជាប់ ឬតំឡើងនូវប្រដាប់ការពារសំលេង<br>• ត្រូវផ្តល់នូវឧបករណ៍ពាក់ត្រចៀកចំពោះអ្នកដែលប្រើរណាអារឈើ ដើម្បីកាត់បន្ថយ គ្រោះនៃការបាត់បង់សមត្ថភាពសោតវិញ្ញាណ | ក្រុមហ៊ុន **បៀន ហៀក អ៊ិនវេសមេន** | – |
| ការចោលសំណល់រឹងផ្សេងៗទៅក្នុងមជ្ឈដ្ឋានជុំវិញ | ធ្វើឱ្យកខ្វក់ដល់មជ្ឈដ្ឋានជុំវិញ | • ចោលកាកសំណល់រឹងទៅក្នុងរណ្តៅជាមួយនឹងការលុបដីជាប្រចាំ។<br>• ប្រសិនបើអាច ចាំបាច់ត្រូវចោលសំរាមនៅក្រៅកន្លែងរស់នៅ តែប្រសិនបើមិនអាចត្រូវជ្រើសរើសកន្លែងណាមួយនៅក្នុងហើយរៀបចំឱ្យបានស្រួលបួល ជៀសវាងការបង្កឱ្យកខ្វក់ដល់ប្រភពទឹក ឬអណ្តូងទឹក ដែលធ្វើឱ្យបាត់បង់សោភ័ណភាព និងមានក្លិនស្អុយ។<br>• រៀបចំល្អសំរាប់ស្តុកកាកសំណល់<br>• ហាមចាក់ប្រេង រូបធាតុរំលាយ ឬប្រេងរំអិលទៅលើដី ស្ទឹង និងប្រព័ន្ធរំដោះទឹកនានា ដែលមាននៅក្នុងតំបន់នោះ។ | ក្រុមហ៊ុន **បៀន ហៀក អ៊ិនវេសមេន** | – |

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តម្លៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ក្នុងពេលប្រតិបត្តិគំរោង - ការឈូសសំអាតព្រៃដើម្បីដាំដំណាំកៅស៊ូ (ត)** | | | | |
| ការឈូសសំអាតព្រៃ | ការធ្វើឱ្យកខ្វក់ដល់ប្រភពទឹក | • ត្រូវលុបបំបាត់នូវរាល់សកម្មភាពទាំងឡាយណា ដែលធ្វើឱ្យប៉ះពាល់ដល់គុណភាពទឹក នៅក្នុងរយះពេលនៃការអនុវត្តន៍គំរោង តាមរយៈការគ្រប់គ្រងអ្នកម៉ៅការនៅក្នុងពេលនៃគំរោង។ ការប្រើប្រាស់នូវគ្រឿងចក្រក៏ដូចជាការដែលឈូសឈើគររួចដែរ ដើម្បីកាត់បន្ថយនូវការបន្ថែមរូបធាតុកខ្វក់ ដូចជាការហូររបស់ដីរចេញពីទីតាំងគំនរឈើសំបូរទៅដោយរូបធាតុ ស៊ុលហ្វីត និងដីរដែលនឹងហូរធ្លាក់ទៅក្នុងប្រព័ន្ធស្ទឹង។<br>• ទាមទារឱ្យមាននូវប្រព័ន្ធមួយដែលមានប្រសិទ្ធិភាព សំរាប់គ្រប់គ្រងការហូរច្រោះខ្សាច់នៅក្នុងពេលសាងសង់នៅក្នុងដំណើរការនៃការរៀបចំផែនការដូចជា ការជីកកប់និងចាក់បំពេញដីឬមួយក៏ការរៀបចំប្រព័ន្ធភ្លឺដើម្បីទប់ស្កាត់ការហូរច្រោះ និងបំណែករបស់ដី។ ក្រៅពីនេះត្រូវផ្អាកការងារនៅក្នុងរដូវវស្សា ព្រោះថាតំបន់មួយចំនួននឹងកើតមាននូវដំណុះរុក្ខជាតិតាមលក្ខណៈធម្មជាតិជាថ្មីវិញ ។<br>• ចំពោះអណ្តូងទឹកនៅក្នុងទីស្នាក់ការស្នូល ត្រូវជីកនូវកន្លែងមួយឆ្ងាយពីកន្លែងដែលមានមនុស្សកកកុញ និងកន្លែងដែលគេប្រើប្រាស់តាមលទ្ធភាពដែលអាចធ្វើទៅបាន ជាពិសេសត្រូវឆ្ងាយពីលូទឹកស្អុយ បង្គន់ និងកន្លែងដែលគេបោះសម្រាមចោល ។ | ក្រុមហ៊ុន **បៀន ហៀក អ៊ិនវេសមេន** | - |

Draft

| សកម្មភាពគំរោង | សក្តានុពលហេតុប៉ះពាល់បរិស្ថាន | ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | ការទទួលខុសត្រូវរបស់ស្ថាប័ន | តម្លៃប៉ាន់ស្មាន |
|---|---|---|---|---|
| **ក្នុងពេលប្រតិបត្តិគំរោង – ការឈូសសំអាតព្រៃដើម្បីដាំដំណាំកៅស៊ូ (ត)** | | | | |
| ការឈូសសំអាតព្រៃ | បាត់បង់ទីជំរក និងប៉ះពាល់ដល់សត្វព្រៃ | • គ្មានវិធានការណាជាក់លាក់ដើម្បីកាត់បន្ថយផលប៉ះពាល់ ដែលកើតឡើងដោយសារការឈូសសម្អាតព្រៃទំហំ៤.៣៨៥ហិកតា នេះទេ។ តំបន់របៀងនេះ នឹងបង្កលក្ខណៈអោយសត្វព្រៃធ្វើបំលាស់ទីពីកន្លែងដែលទទួលរងការរំខាន ទៅកន្លែងផ្សេងទៀត។ មិនត្រឹមតែប៉ុណ្ណោះ អាចដើរតួនាទីជាទីតាំងយុទ្ធសាស្រ្ត សម្រាប់ថនិកសត្វ តូចៗមួយចំនួនលាក់ខ្លួនបានងាយស្រួលទៀតផង។<br>• គ្មានវិធានការមានប្រសិទ្ធិភាពជាក់លាក់សម្រាប់ការពារពពួកឧរង្គសត្វមួយចំនួន ដូចជាអាញ្ញី ពីការកាប់ព្រលំឈើនោះទេ។ សត្វដែលរងគ្រោះដោយសារការកាប់ព្រលំឈើ ត្រូវយកទៅរក្សាទុកនៅការិយាល័យសត្វព្រៃ របស់រដ្ឋបាលព្រៃឈើខេត្ត។<br>• តំបន់ទ្រនាប់ប្រព័ន្ធផ្លូវទឹកត្រូវរក្សា និងការពារអោយបានត្រឹមត្រូវ ដើម្បីការពារនឹងទប់ស្កាត់ការហូរច្រោះ និងការរក្សាបាននូវទីកន្លែងបត្តពូជរបស់ពពួកមច្ឆាជាតិ។ | ក្រុមហ៊ុន **បៀន ហៀក អ៊ិនវេសមេន** | - |
| **ផលប៉ះពាល់ក្រោយពេលដាំដុះ** | | | | |
| ការថែរក្សាកូនកៅស៊ូ | ដុះខ្សាច់ និងល្អក់ទឹក | • ដោយសារក្រុមហ៊ុនមានផែនការប្រើប្រាស់ដីត្រឹមត្រូវ ដូច្នេះមិនចាំបាច់មានវិធានការអ្វីថែមទៀតទេ | ក្រុមហ៊ុន **បៀន ហៀក អ៊ិនវេសមេន** | - |

Draft

១៨៤. ថវិកាសរុបដែលគ្រោងសម្រាប់ប្រើប្រាស់ក្នុងការអនុវត្តន៍ផែនការគ្រប់គ្រងបរិស្ថាន នៅក្នុងរយៈពេល ០៥ឆ្នាំនៃការអភិវឌ្ឍន៍ មានចំនួនសរុប **២.៨៥១.០០០** ដុល្លារ។ ថវិកានោះត្រូវប្រើសម្រាប់៖ (១) រៀបចំប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ (២) គ្រប់គ្រងតំបន់ទ្រនាប់ (៣) ប្រាក់បរិច្ចាកដើម្បីអភិវឌ្ឍន៍សហគមន៍ និងស្តារបរិស្ថាន និង (៤) អនុវត្តន៍កម្មវិធីត្រួតពិនិត្យ និងវាយតម្លៃ។ ចំណែកឯថវិកាបំរុងសម្រាប់ការជួសជុល បរិស្ថាននៅក្នុងករណីចាំបាច់ផ្សេងៗ និងថវិកាបំរុងសម្រាប់ឧបត្ថម្ភសមាជិកគ្រួសារប្រជាពលរដ្ឋនៅក្នុងសហគមន៍ និងបុគ្គលិកកម្មករដែលមានគ្រោះថ្នាក់ដោយចៃដន្យនៅក្នុងរយៈពេលនៃប្រតិបត្តិការ មិនបានដាក់បញ្ចូលទៅក្នុងតារាងតម្លៃប៉ាន់ស្មានសំរាប់ការអនុវត្តន៍ និងតាមដានពិនិត្យវាយតម្លៃនោះទេ។ ប៉ុន្តែ ក្រុមហ៊ុនត្រូវមានថវិកាបំរុងគ្រប់គ្រាន់ សំរាប់គំរោងថវិកានេះ នៅក្នុងករណីនៃឧបទ្ទវហេតុដែលអាចកើតមានឡើងជាយថាហេតុ (សូមមើលតារាង ៦-២)។

តារាង ៦-២: **តម្លៃប៉ាន់ស្មានសម្រាប់ការអនុវត្តន៍ EMP និងការត្រួតពិនិត្យតាមដាន**

| កម្មវិធី | សកម្មភាព | ចំនួន | តម្លៃ (ដុល្លា) | |
|---|---|---|---|---|
| | | | ឯកតា | សរុប |
| ហេដ្ឋារចនាសម្ព័ន្ធ | រៀបចំគំរោង | ០១ | ១២០.០០០ | ១២០.០០០ |
| | ស្នាក់ការមេ និងកន្លែងបណ្តុះកូនកៅស៊ូ | ០១ | ១២០.០០០ | ១២០.០០០ |
| | ស្នាក់ការរង | ០៣ | ៤០.០០០ | ១២០.០០០ |
| | ប៉មយាមភ្លើង | ១៤ | ២.០០០ | ២៨.០០០ |
| | ប៉ុស្តិ៍ល្បាត | ០២ | ១.៥០០ | ៣.០០០ |
| | ប៉ុស្តិ៍សុវត្ថភាព | ០២ | ២.៥០០ | ៥.០០០ |
| | មណ្ឌលសុខភាព | ០១ | ៦០.០០០ | ៦០.០០០ |
| | សាលារៀន | ០១ | ១២៥.០០០ | ១២៥.០០០ |
| | ប្រព័ន្ធផ្លូវ (គ.ម) | ២៥៦ | ១.៨០០.០០០ | ១.៨០០.០០០ |
| | **សរុប** | | | **២.៣៨១.០០០** |
| គ្រប់គ្រងតំបន់ទ្រនាប់ | ស្ថានីយ៍ល្បាតអចិន្ត្រៃយ៍ | ០៣ | ៩០០ | ២.៧០០ |
| | ភ្នាក់ល្បាត (៧២ខែ) | ០២/ស្ថានីយ៍ | ១៥០ | ២១.៦០០ |
| | មធ្យោបាយ និងភស្តុភា | ០១/ស្ថានីយ៍ | ៥០០ | ១.៥០០ |
| | **សរុប** | | | **២៩.៨០០** |
| ប្រាក់បរិច្ចាកសង្គម និងបរិស្ថាន | ថវិកាបរិច្ចាកសម្រាប់អភិវឌ្ឍន៍សហគមន៍ | ០៥ឆ្នាំ | ២៥.០០០ | ១២៥.០០០ |
| | ថវិកាបរិច្ចាកសម្រាប់ស្តារបរិស្ថាន | ០៦ឆ្នាំ | ៣០.០០០ | ១៨០.០០០ |

| | | | | |
|---|---|---|---|---|
| | សរុប | | | **៣០៥.០០០** |
| ការត្រួតពិនិត្យ | LEC (៧២ខែ) | ០១ | ៣០០ | ២១.៦០០ |
| | នាយកដ្ឋាន EIA (០៣នាក់) | ០៣ខែម្តង | ១.៥០០ | ៣៦.០០០ |
| | នាយកដ្ឋាន EIA និងគណកម្មការអន្តរៈក្រសួង | ០៦ខែម្តង | ៥.០០០ | ៦០.០០០ |
| | តេស្ត៍ | ០៦ខែម្តង | ១.៨០០ | ២១.៦០០ |
| | **សរុប** | | | **១៣៩.២០០** |
| | **សរុបរួម** | | | **២.៨៥១.០០០** |

**១៨៥.** អ្នកសម្របសម្រួលបរិស្ថានរបស់ក្រុមហ៊ុន (Local Environmental Coordinator - LEC) នឹងត្រូវតាមដានត្រួតពិនិត្យនូវហេតុប៉ះពាល់ នឹងធ្វើរបាយការណ៍រៀងរាល់ខែ នៅក្នុងអាយុកាលនៃការប្រតិបត្តិគំរោង ដើម្បីធានាបានថាដំណើរប្រតិបត្តិនេះ បានអនុវត្តទៅតាមផែនការគ្រប់គ្រងបរិស្ថាន ដូចមានកំណត់នៅក្នុងតារាង៦-១។ ម្ចាស់គំរោងមិនត្រូវចាប់ផ្តើមដំណើរការគំរោងមុនពេលដែលក្រសួងបរិស្ថាន ផ្តល់ការអនុម័តជាផ្លូវការឡើយ។

**១៨៦.** ការតាមដានត្រួតពិនិត្យវាយតំលៃគំរោង ត្រូវធ្វើទៅតាមតម្រូវការនៃការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន ដូចបានសង្ខេបនៅក្នុងតារាង៦-៣។ ម្ចាស់គំរោងត្រូវធ្វើសាវនកម្មផ្ទៃក្នុងរៀងរាល់១ខែម្តង ទៅលើការអនុវត្តន៍ EMP លើដំណើរការប្រតិបត្តិទាំងមូល។ នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នឹងធ្វើការត្រួតពិនិត្យ វាយតម្លៃទៅលើការអនុវត្តន៍ EMP រៀងរាល់៣ខែម្តង។ ចំណែកឯគណៈកម្មការអន្តរក្រសួង ដែលដឹកនាំដោយក្រសួងបរិស្ថាន និងមានការចូលរួមពីសំណាក់មន្ត្រីសមត្ថកិចមូលដ្ឋាន (ខេត្ត ស្រុក) នឹងធ្វើការត្រួតពិនិត្យ និងវាយតម្លៃ រៀងរាល០៦ខែម្តង។ ស្ថាប័នជំនាញក៏មានតួនាទីទទួលខុសត្រូវក្នុងការពិនិត្យលើនីតិវិធីប្តឹងតវ៉ាដើម្បីធានាបានថា ការផ្តល់ប្រាក់ឧបត្ថម្ភចំពោះបុគ្គលិក/កម្មករ ដែលរងគ្រោះទទួលការដោះស្រាយបានត្រឹមត្រូវពីម្ចាស់ក្រុមហ៊ុនឬមួយយ៉ាងណា ដើម្បីរាយការណ៍ទៅក្រសួងបរិស្ថាន។

**១៨៧.** ម្ចាស់ក្រុមហ៊ុនត្រូវធ្វើការបណ្តុះបណ្តាលអំពីបទដ្ឋាននៃការគ្រប់គ្រងបរិស្ថាន គោលនយោបាយផែនការ និងនីតិវិធីនៃការអនុវត្តន៍និងការត្រួតពិនិត្យតាមដានដំណើរប្រតិបត្តិការគំរោងដល់បុគ្គលិករបស់ខ្លួន ឬក៏អ្នកម៉ៅការបន្ត។ អ្នកជំនាញបរិស្ថានត្រូវរៀបចំសៀវភៅប្រតិបត្តិសង្ខេបដល់អ្នកសម្របសម្រួបបរិស្ថាននៅមូលដ្ឋាន ហើយត្រូវត្រួតពិនិត្យវាយតំលៃ និងផ្តល់នូវមតិយោបល់ផ្សេង១ដល់ម្ចាស់ក្រុមហ៊ុន ថាតើអ្នកបច្ចេកទេសបរិស្ថាន របស់ក្រុមហ៊ុនគួរមានសមត្ថភាពកំរិតណាដើម្បីធានាបានដល់ការអនុវត្តន៍ និងការគ្រប់គ្រងការងារទាំងអស់នោះ។

Draft

**តារាង ៦-៣: សង្ខេបអំពីតំរូវការនៃការត្រួតពិនិត្យការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន**

| ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ខួបនៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **ផលប៉ះពាល់មុនពេលប្រតិបត្តិគំរោង - ក្នុងដំណាក់កាលរៀបចំគំរោង** | | | | | | |
| • ប្រើទស្សនៈនៃការអភិវឌ្ឍន៍ជាប្រព័ន្ធ ដោយមានការបែងចែកផលធៀបប្រើប្រាស់ដីបានត្រឹមត្រូវ | ការធ្វើគំរោង | ការិយាល័យ | ផលធៀបប្រើប្រាស់ដី | ម្តងក្រោយពេល | ក្រុមហ៊ុន **បៀន ហៀក អ៊ិនវេសមេន** | ១២០.០០០ |
| **មុនពេលប្រតិបត្តិគំរោង - ការរៀបចំផែនការសុខភាព និងសុវត្ថិភាពការងារ** | | | | | | |
| • ស្វែងរក តាមដានលក្ខណៈគ្លីនិកអ្នកផ្ទុកជំងឺឱ្យបានទាន់ពេលវេលា<br>• ផ្តល់ការព្យាបាលឱ្យបានត្រឹមត្រូវនៅគ្រប់ករណីនៃការកើតមានទាំងអស់<br>• ធ្វើរបាយការណ៍អំពីការកើតមាន និងតាមដានអ្នកដែលប៉ះពាល់ជាមួយនឹងអ្នកជំងឺ<br>• ផ្តល់ការណែនាំអំពីការប្រើថ្នាំការពារជំងឺគ្រុនចាញ់ឱ្យបានត្រឹមត្រូវ<br>• ជ្រលក់មុងជាមួយនឹងរបាយ Pyrathroid<br>• អនុវត្តន៍គំរោងកែលំអអនាម័យ ដើម្បីបំបាត់កន្លែងរស់នៅរបស់មូស និងផ្តល់ការអប់រំអំពីបញ្ហាសុខភាព និងការការពារជំងឺគ្រុនចាញ់<br>• ដាក់សំណាញ់តាមទ្វារ បង្អួចផ្ទះ និងប្រើមុងជាប្រចាំ<br>• ស្លៀកពាក់ខោអាវដៃវែង និងប្រើថ្នាំការពារមូស<br>• តាមដានគ្លីនិក និងរោគសញ្ញារបស់ជំងឺ<br>• ធ្វើរោគវិនិច្ឆ័យ និងផ្តល់ការព្យាបាល ឱ្យបានទាន់ពេលវេលា និង<br>• ត្រួតពិនិត្យនូវឧប្បត្តិហេតុ និងកំណត់ទីកន្លែងកើតមានជំងឺ | វិធីសាស្ត្រការពារជំងឺគ្រុនចាញ់ | ការិយាល័យ | មានការរៀបចំវិធីសាស្ត្រការពារបានត្រឹមត្រូវល្អ និងការអនុវត្តន៍បានត្រឹមត្រូវទៅតាមវិធីសាស្ត្រនានាដែលរៀបចំឡើង | ម្តងមុនចាប់ពេលផ្តើម និង៣ខែម្តងក្រោយពេលចាប់ផ្តើមគំរោង | ក្រុមហ៊ុន **បៀន ហៀក អ៊ិនវេសមេន** | ដកពីខ្ទង់ចំណាយផ្សេង១ និងប្រាក់ធានារ៉ាប់រងសង្គម ដែលមានទឹកប្រាក់សរុបប្រមាណ ២៦០.០០០ដុល្លា ក្នុងមួយឆ្នាំ (ផែនការមេ) |

| ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ខួបនៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **មុនពេលប្រតិបត្តិគំរោង – ការរៀបចំផែនការសុខភាព និងសុវត្ថិភាពការងារ (ត)** | | | | | | |
| • ត្រូវបំបែកអ្នកជំងឺឱ្យនៅកន្លែងផ្សេង និងផ្តល់ការព្យាបាលជាពិសេសទៅតាមយថាប្រភេទនៃជំងឺ ។<br>• បាញ់ថ្នាំក្នុងបរិវេណរស់នៅចំងាយ២០០ម ដើម្បីសម្លាប់មូសពេញវ័យ ។<br>• ស្វែងរក និងបំផ្លាញទីតាំងជម្រកមូស ។<br>• ចាំបាច់ត្រូវប្រើថ្នាំសំលាប់ពងមូសចំពោះទីកន្លែងដែលមានមូសច្រើន ។<br>• អប់រំដល់បុគ្គលិកកម្មករ និងសហគមន៍អំពីវិធានការគ្រប់គ្រងការរាគត្បាត ។ | វិធានការគ្រប់គ្រងការរាគត្បាត | ការិយាល័យ | មានការរៀបចំវិធីសាស្ត្រការពារបានត្រឹមត្រូវល្អ និងការអនុវត្តន៍បានត្រឹមត្រូវទៅតាមវិធីសាស្ត្រនានាដែលរៀបចំឡើង | ម្តងមុនចាប់ពេលផ្តើម និង៣ខែម្តងក្រោយពេលចាប់ផ្តើមគំរោង | ក្រុមហ៊ុន បៀន ហៀក អ៊ិនវេសមេន | ដកពីខ្ទង់ចំណាយផ្សេងៗ និងប្រាក់ធានារ៉ាប់រងសង្គមដែលមានទឹកប្រាក់សរុបប្រមាណ ២៦០.០០០ដុល្លាក្នុងមួយឆ្នាំ (ផែនការមេ) |

| ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ខួបនៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **មុនពេលប្រតិបត្តិគំរោង – ការរៀបចំផែនការសុខភាព និងសុវត្ថិភាពការងារ (ត)** | | | | | | |
| • ក្រុមហ៊ុនត្រូវផ្តល់ទឹកស្អាតដល់កម្មករ ។<br>• ត្រួតពិនិត្យជាប្រចាំ អំពីគុណភាពរបស់ទឹក (វត្តមានរបស់បាក់តេរី សារធាតុគីមី និងពណ៌របស់ទឹក)<br>• ត្រូវធ្វើរោគវិនិច្ឆ័យ និងផ្តល់ការព្យាបាលឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា ។<br>• តាមដានរកប្រភពចំលង និងផ្តល់ការព្យាបាល ។<br>• ធានាឱ្យបាននូវសុវត្ថិភាព និងសម្អាតសំរាម និងការទុកដាក់នូវសំណល់រឹង នៅក្នុងផ្ទះដែលសង់សំរាប់កម្មករ ។<br>• កែលំអការសម្អាត បរិស្ថាននៅក្នុងបរិវេណទីស្នាក់ការ និងទីកន្លែងរស់នៅ ដោយការសង់បង្គន់អនាម័យ និងកន្លែងសំរាប់ទុកដាក់សំណល់រឹង ។<br>• កែលំអអនាម័យបុគ្គល ជាពិសេសចំពោះអ្នករៀបចំអាហារ ។<br>• ផ្តល់វ៉ាក់សាំងចំពោះបុគ្គលិក ឬកម្មករបរទេសដែលពុំមានអង់ទីករប្រឆាំងជំងឺគ្រុនពោះវៀន អាសន្នរោគ និងរលាកថ្លើម ។<br>• រាយការណ៍នឹងធ្វើការត្រួតពិនិត្យអំពីឧប្បត្តិហេតុរបស់ជំងឺ ។ | វិធានការការពារជំងឺដែលបង្កឡើងដោយការប្រើប្រាស់ទឹកមិនស្អាត | ការិយាល័យ | មានការរៀបចំវិធីសាស្ត្រការពារបានត្រឹមត្រូវល្អ និងការអនុវត្តន៍បានត្រឹមត្រូវទៅតាមវិធីសាស្ត្រនានាដែលរៀបចំឡើង | ម្តងមុនចាប់ពេលផ្តើម និង៣ខែម្តងក្រោយពេលចាប់ផ្តើមគំរោង | ក្រុមហ៊ុន បៀន ហៀក អិនវេសមេន | ដកពីខ្ទង់ចំណាយផ្សេងៗ និងប្រាក់ធានារ៉ាប់រងសង្គម ដែលមានទឹកប្រាក់សរុបប្រមាណ ២៦០.០០០ដុល្លា ក្នុងមួយឆ្នាំ (ផែនការមេ) |

| ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ខួបនៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **មុនពេលប្រតិបត្តិគំរោង - ការរៀបចំផែនការសុខភាព និងសុវត្ថិភាពការងារ (ត)**<br>• អប់រំបុគ្គលិក កម្មករអំពីគ្រោះថ្នាក់នៃការឆ្លងជំងឺអេដស៍ និងជំងឺផ្លូវភេទផ្សេងៗទៀត ដូចជាការទប់ស្កាត់នូវទំនាក់ទំនងជាមួយអ្នកដែលធ្វើអាជីវកម្មលើផ្លូវភេទ ការប្រើប្រាស់ស្រោមអនាម័យ ណែនាំអ្នកជំងឺឱ្យព្យាបាលជាមួយនឹងគ្រូពេទ្យដែលមានបទពិសោធន៍ និងមិនត្រូវព្យាបាលដោយខ្លួនឯង។<br>• រាយការណ៍អំពីអ្នកជំងឺ ស្វែងរកអ្នកចំលង និងត្រួតពិនិត្យករណីនៃការកើតមានរបស់ជំងឺ ដោយការិយាល័យសុខាភិបាលនៅក្នុងតំបន់។ ប្រសិទ្ធិភាពនៃកម្មវិធីការពារជំងឺផ្លូវភេទទាមទារឱ្យមានកិច្ចសហប្រតិបត្តិការរវាង អាជ្ញាធរសុខាភិបាល អាជ្ញាធរ និងសហគមន៍មូលដ្ឋាន និងក្រុមហ៊ុន។ | វិធានការការពារជំងឺផ្លូវភេទ | ការិយាល័យ | មានការរៀបចំវិធីសាស្ត្រការពារបានត្រឹមត្រូវល្អ និងការអនុវត្តន៍បានត្រឹមត្រូវទៅតាមវិធីសាស្ត្រនានាដែលរៀបចំឡើង | ម្តងមុនចាប់ពេលផ្តើម និង៣ខែម្តងក្រោយពេលចាប់ផ្តើមគំរោង | ក្រុមហ៊ុន បៀន ហៀក អ៊ិនវេសមេន | ដកពីខ្ទង់ចំណាយផ្សេងៗ និងប្រាក់ធានារ៉ាប់រងសង្គម ដែលមានទឹកប្រាក់សរុបប្រមាណ ២៦០.០០០ដុល្លាក្នុងមួយឆ្នាំ (ផែនការមេ) |

Draft

Draft

| ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ខួបនៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **មុនពេលប្រតិបត្តិគំរោង - ការរៀបចំផែនការសុខភាព និងសុវត្ថិភាពការងារ (ត)** | | | | | | |
| • ក្រុមហ៊ុនត្រូវរៀបចំប្លង់កសាងទីស្នាក់ស្នូលឱ្យបានត្រឹមត្រូវ<br>• ត្រូវផ្តល់ផ្ទះដល់កម្មករទៅតាមល័ក្ខខ័ណ្ឌ:<br>• លក្ខណ:រូប: ទីតាំងផ្ទះ ចាំបាច់ត្រូវស្ថិតនៅផុតពីកំពស់ទឹកជំនន់ ស្ថិតនៅឆ្ងាយពីទី កន្លែងដែលអាចផ្តល់ភាពកខ្វក់ និងកន្លែងដែលមានសត្វល្អិតច្រើន។ ផ្ទះកម្មករត្រូវមានសំណាញ់ការពារមូសនិងមានឆ្នាំការពារចោរ ហើយត្រូវមានពន្លឺគ្រប់គ្រាន់។ ម្យ៉ាងវិញទៀត ទីតាំងរបស់ផ្ទះ និងបន្ទប់ត្រូវមានចរន្តខ្យល់គ្រប់គ្រាន់ (ផ្ទៃបន្ទប់ត្រូវបើកចំហរយ៉ាងតិច១០ភាគរយ)។<br>• លក្ខណ:អនាម័យ: ផ្តល់ទឹកស្អាតឱ្យបានគ្រប់គ្រាន់ ជាមួយនឹងមធ្យោបាយសំរាប់ដុសលាងនិងងូតទឹក សង់បង្គន់អនាម័យ និងកន្លែងសំរាប់ទុកដាក់សំណល់រឹងត្រឹមត្រូវ។<br>• ពិនិត្យអំពីលទ្ធភាពនៃការផ្តល់កន្លែងសំរាប់លំហែ (តារាងបាល់បោះ បាល់ទះ និងបាល់ទាត់) និងមណ្ឌលសុខភាព។ | មានសមាហរ័ណកម្មបរិស្ថាន និងសុខភាព | ការិយាល័យ | មានការរៀបចំត្រឹមត្រូវទៅតាមគោលការណ៍សមាហរ័ណកម្មបរិស្ថាន និងសុខភាព | ម្តងមុនចាប់ពេលផ្តើម និង៣ខែម្តងក្រោយពេលចាប់ផ្តើមគំរោង | ក្រុមហ៊ុន បៀន ហៀក អ៊ិនវេសមេន | ដកពីខ្ទង់ចំណាយផ្សេងៗ និងប្រាក់ធានារ៉ាប់រងសង្គម ដែលមានទឹកប្រាក់សរុបប្រមាណ ២៦០.០០០ដុល្លា ក្នុងមួយឆ្នាំ (ផែនការមេ) |
| • ការរៀបចំផែនការសុខភាព និងសុវត្ថិភាពការងារ ការផ្តល់នូវការបណ្តុះបណ្តាលផ្សេងៗ និងការណែនាំដល់បុគ្គលិកកម្មករទាំងអស់មុនពេលប្រគល់ភារកិច្ចផ្សេងៗ។ | សុខភាពការងារ និងផែនការសុវត្ថិភាព | ការិយាល័យ | បុគ្គលិកទាំងអស់ទទួលបានការបណ្តុះបណ្តាលពេញលេញ | ម្តងមុនចាប់ពេលផ្តើម និង៣ខែម្តងក្រោយពេលចាប់ផ្តើមគំរោង | ក្រុមហ៊ុន បៀន ហៀក អ៊ិនវេសមេន | - |

| ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ខួបនៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **មុនពេលប្រតិបត្តិគំរោង - ការដោះស្រាយបញ្ហាកម្មសិទ្ធិដី** | | | | | | |
| • ការដោះស្រាយបញ្ហាកម្មសិទ្ធិដីត្រូវមានលក្ខណៈគតិយុត្តិ ដោយផ្អែកទៅលើលទ្ធភាពនៃការប្រើប្រាស់ដី និងឬទិន្នផលដែលម្ចាស់ដីធ្លាប់ទទួលបានពីមុន ។ | ម្ចាស់ដីពាក់ព័ន្ធបានទទួលការដោះស្រាយ | ទីវាល | ម្ចាស់ដីពាក់ព័ន្ធបានទទួលការដោះស្រាយ | ម្តងមុនពេលអនុវត្តន៍គំរោង | ក្រុមហ៊ុន បឿន ហៀក អិនវេសមេន | តាមជាក់ស្តែង |
| **មុនពេលប្រតិបត្តិគំរោង - ការរៀបចំទីតាំងសំរាប់ចត គ្រឿងចក្រ** | | | | | | |
| • កិនបង្ហាប់ទីតាំង នោះឱ្យបានហាប់ល្អ និង<br>• ក្រាលគ្រួសក្រហមពីលើឱ្យបានកំរាស់ពី ១០-១៥ស.ម ហើយកិនបង្ហាប់ឱ្យល្អ ។ | ផែនការសាងសង់ | ទីវាល | បង្កការកខ្វក់ដល់មជ្ឈដ្ឋានជុំវិញ ដោយការលើកដីរៀបចំទីតាំងចត គ្រឿងចក្រ | ម្តងមុន ក្នុងពេល និងក្រោយពេលអនុវត្តន៍គំរោង | ស្ថាប័នជំនាញ | ១៥.០០០ |
| **មុនពេលប្រតិបត្តិគំរោង - ទីតាំងរោងជាង និងកន្លែងស្តុកប្រេង** | | | | | | |
| កន្លែងរក្សាប្រេងឥន្ធនៈ និងប្រេងរំអិលផ្សេងៗសំរាប់ការសាងសង់ និងសំភារៈគ្រោះថ្នាក់ដទៃ ទៀតចាំបាច់ត្រូវរក្សាឱ្យផុតពីកម្រិតកំពស់ទឹកជំនន់ ហើយនឹងមានចំងាយយ៉ាងតិច៣០-៥០ ម៉ែត្រពីប្រភពទឹកដូចជា: ប្រព័ន្ធផ្លូវទឹក ប្រឡាយ និង ស្រះទឹក ជាដើម ។ កន្លែងស្តុកប្រេងនិងរោង ជាងត្រូវសង់ឱ្យខ្ពស់ជាងកំរិតកំពស់ទឹកជំនន់ និងស្ថិតនៅក្នុងកន្លែងមួយដែលមានសុវត្ថិភាព ហើយការពារ ដោយអាងរក្សាប្រេងបិទជិតមួយដែលមានលទ្ធភាពគ្រប់គ្រាន់អាចស្តុកប្រេង ដែលហូរចេញពីកន្លែងស្តុកប្រេង បាន ។ | ផែនការសាងសង់ | ទីវាល | បង្កការកខ្វក់ដល់មជ្ឈដ្ឋានជុំវិញ ដោយការលើកដីរៀបចំទីតាំងចត គ្រឿងចក្រ | បីខែម្តង | ស្ថាប័នជំនាញ | ២០.០០០ |

| រលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ខួបនៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **មុនពេលប្រតិបត្តិគំរោង – ការសាងសង់ទីស្នាក់ការស្នូល និងប្រព័ន្ធផ្លូវនៅក្នុងតំបន់សម្បទាន** | | | | | | |
| • ឈូសរុក្ខជាតិដែលមាននៅទីនោះទៅគរទុកឱ្យមានសណ្តាប់ធ្នាប់ ពេលស្ងួតអាចដុតចោល ឬមួយក៏ចលនាឱ្យប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់នោះប្រមូលយកទុកប្រើប្រាស់ជាឧស<br>• មិនត្រូវឈូសរុក្ខជាតិទាំងនោះទៅគរទុកលើប្រព័ន្ធផ្លូវទឹក (ប្រឡាយឬអូរ) ដែលអាចបង្កឱ្យមាន ការស្ទះដល់ចរន្តទឹកទេ និង<br>• រុក្ខជាតិធំៗ ត្រូវប្រើប្រាស់ទៅតាមលទ្ធភាពដែលអាចប្រើបាន។ | វិធីសាស្ត្រឈូសឆាយ | ទីវាល | បង្កការកខ្វក់ដល់មជ្ឈដ្ឋានជុំវិញដោយសកម្មភាពឈូសឆាយព្រៃ | ០៣ខែម្តង<br>០៦ខែម្តង | នាយកដ្ឋាន EIA<br>គណកម្មការអន្តរៈក្រសួង | ១.៥០០<br>៦.០០០ |
| • កាត់បន្ថយល្បឿនរបស់គ្រឿងចក្រ<br>• ចៀសវាងការធ្វើការនៅពេលយប់<br>• កំណត់ពេលវេលានៃប្រតិបត្តិការទាំងឡាយណាដែលមានសំលេងខ្លាំង<br>• ពិនិត្យ និងតាមដានគ្រឿងចក្រឱ្យបានញឹកញាប់ និងដូរគ្រឿងបំលាស់ថ្មីចំពោះកន្លែងខូចខាត ដែលជាមូលហេតុនាំឱ្យមានសំលេងខ្លាំងខុសប្រក្រតី<br>• ត្រូវភ្ជាប់ ឬតំឡើងនូវប្រដាប់ការពារសំលេង<br>• ត្រូវផ្តល់នូវឧបករណ៍ពាក់ត្រចៀកចំពោះអ្នកដែលប្រើរណាអារឈើ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ នៃការបាត់បង់សមត្ថភាពសោតវិញ្ញាណ<br>• ធ្វើមផ្លូវដោយការស្រោចទឹកជាប្រចាំ | សកម្មភាពគ្រឿងចក្រ | ទីវាល | បង្កការរំខានដល់អារមណ្ឌ ប្រព័ន្ធសោតវិញ្ញាណ និងប្រព័ន្ធដកដង្ហើម និងការលូតលាស់របស់រុក្ខជាតិ | - | - | - |

Draft

| ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ខួបនៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **មុនពេលប្រតិបត្តិគំរោង - ការសាងសង់ប្រព័ន្ធផ្លូវនៅក្នុងតំបន់សម្បទាន** | | | | | | |
| • រក្សានូវមុំរបស់ផ្លូវ ទៅតាមផែនការវិស្វកម្មព្រៃឈើ (មិនធំជាង១០ភាគរយចំពោះដីជ្រាយ និង មិនធំជាង១៤ភាគរយចំពោះដីរឹង)<br>• ចៀសវាងទីជំរាលវែង ដែលជាកន្លែងទឹកហូរចេញពីទ្រូងផ្លូវ។ នៅកន្លែងដែលទីជំរាលវែងមិនអាចចៀសវាងបាន ត្រូវជីកចង្អូរកាត់ទីជំរាល ចាក់ដីខ្សាច់ក្រាលនិងជីកចង្អូរនៅតាមដងផ្លូវ<br>• ត្រូវកាយចង្អូរនៅតាមដងផ្លូវ ហើយទ្រូងផ្លូវត្រូវមានរាងជាខ្នងអណ្តើក ដើម្បីឱ្យងាយហូរធ្លាក់ទៅចង្អូរ។<br>• ជៀសវាងការដឹកជញ្ជូននៅក្នុងពេលកំពុងភ្លៀងឬនៅក្នុងសណ្ឋានភាពសើម<br>• ខ្នងផ្លូវត្រូវក្រាលថ្មបាយក្រៀមឬក៏កំទេចថ្ម<br>• ប្រើប្រាស់គ្រឿងចក្រឱ្យបានសមស្របដើម្បីកាត់បន្ថយហេតុប៉ះពាល់ពីការដាច់ដី<br>• ការពារតំបន់រណបរបស់អូរ និងស្ទឹង: រុក្ខជាតិដែលដុះនៅតាមដងស្ទឹងចាំបាច់ត្រូវរក្សាទុកទាំងស្រុងដើម្បីការពារផ្លូវទឹកនិងជីវិតនៅក្នុងទឹក។ ពាក់ព័ន្ធនឹងបញ្ហានេះ ក្រុមហ៊ុនត្រូវតែរក្សាទុក ផ្ទៃដី ដែលក្នុងនោះតំបន់ទ្រនាប់ នៅអមបណ្តោយ ប្រព័ន្ធស្ទឹង និងតាមដៃសំខាន់នានា។ នេះគឺជាវិធានការណ៍មួយដែល មានប្រសិទ្ធិភាពបំផុតក្នុងការកាត់បន្ថយហេតុប៉ះពាល់តាមប្រព័ន្ធស្ទឹង។ | ការច្រោះដី និងការដុះដី | ទីវាល | ការច្រោះដី និងការដុះដី | - | - | - |

| ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ខួបនៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **ក្នុងពេលប្រតិបត្តិគំរោង - ការឈូសសំអាតព្រៃដើម្បីដាំដំណាំកសិឧស្សាហកម្ម** | | | | | | |
| • ការរៀបចំរណ្តៅលើផ្ទៃដីដែលឈូសហើយមិនត្រូវប្រើវិធីភ្ជួរទេ ព្រោះការភ្ជួរនេះធ្វើឱ្យដីបែក ខ្លាំងនេះនឹងបង្កឱ្យការហូរច្រោះនឹងសិកដាច់មានកំរិតខ្ពស់ ។<br>• ការប្រើវិធីខួងដីធ្វើរណ្តៅដាំកូនឈើ អាចទប់ស្កាត់ការហូរច្រោះនឹងសឹកដាច់បានប្រសើរ ហើយការប្រើវិធីនេះធ្វើឱ្យអស់សោហ៊ុយតិចហើយលឿនទៀតផង ។ | ការច្រោះដី និងការដុះដី | ទីវាល | ការច្រោះដី និងការដុះដី | - | - | - |
| **ក្នុងពេលប្រតិបត្តិគំរោង-ប្រតិបត្តិការដាំដុះ** | | | | | | |
| • កំណត់ពេលវេលាដាំដុះឱ្យបានត្រឹមត្រូវតាមរដូវកាល ពោលគឺពីចន្លោះខែឧសភាទៅខែតុលា ។<br>• រៀបកម្លាំងការងារ (ទាំងមនុស្សនិងគ្រឿងចក្រ) ឱ្យបានត្រឹមត្រូវទៅតាមសមាមាត្រជាមួយ នឹងចំហំការងារ ។<br>• មុននឹងចាប់ផ្តើមប្រតិបត្តិការ កម្លាំងពលករទាំងអស់ត្រូវបណ្តុះបណ្តាលឱ្យបានដិតដល់ដោយ ការសាកល្បងផ្ទាល់លើការងារ ( បទពិសោធន៍ សុខភាព សុវត្ថិភាព និងបញ្ហាបរិស្ថាន ។ | ការច្រោះដី និងការដុះដី | ទីវាល | ការច្រោះដី និងការដុះដី | - | - | - |

| ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ខួបនៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **ក្នុងពេលប្រតិបត្តិគំរោង — សម្លេងនិងធូលី**<br>• កាត់បន្ថយល្បឿនរបស់គ្រឿងចក្រ និងចៀសវាងការធ្វើការនៅពេលយប់<br>• កំណត់ពេលវេលានៃប្រតិបត្តិការទាំងឡាយណាដែលមានសំលេងខ្លាំង<br>• ពិនិត្យនិងតាមដានគ្រឿងចក្រឱ្យបានញឹកញាប់ និងដូរគ្រឿងបំលាស់ថ្មីចំពោះកន្លែងខូចខាត ដែលជាមូលហេតុនាំឱ្យមានសំលេងខ្លាំងខុសប្រក្រតី<br>• ត្រូវភ្ជាប់ឬតំឡើងនូវប្រដាប់ការពារសំលេង<br>• ត្រូវផ្តល់នូវឧបករណ៍ពាក់ត្រចៀកចំពោះអ្នកដែលប្រើរណាអារឈើ ដើម្បីកាត់បន្ថយគ្រោះ នៃការបាត់បង់សមត្ថភាពសោតវិញ្ញាណ<br>• ផ្សើមផ្លូវដោយការស្រោចទឹកជាប្រចាំ | សកម្មភាពគ្រឿងចក្រ | ទីវាល | បង្កការរំខានដល់អារមណ្ឌ ប្រព័ន្ធសោតវិញ្ញាណ និងប្រព័ន្ធដកដង្ហើម និងការលូតលាស់របស់រុក្ខជាតិ | - | - | - |
| **ក្នុងពេលប្រតិបត្តិគំរោង – ការចោលសំណល់រឹងផ្សេងៗទៅក្នុងមជ្ឈដ្ឋានជុំវិញ**<br>• ចោលសំណល់រឹងទៅក្នុងរណ្តៅជាមួយនឹងការលុបដីជាប្រចាំ ។<br>• ប្រសិនបើអាចចាំបាច់ត្រូវចោលសំរាមនៅក្រៅកន្លែងរស់នៅ តែប្រសិនបើមិនអាចត្រូវជ្រើសរើសកន្លែងណាមួយនៅក្នុងហើយរៀបចំឱ្យបានស្រួលបួល ចៀសវាងការបង្កឱ្យកខ្វក់ដល់ប្រភពទឹកឬអណ្តូងទឹក ដែលធ្វើឱ្យបាត់បង់សោភ័ណភាព និងមានក្លិនស្អុយ ។<br>• រៀបចំលូសំរាប់ស្តុកសំណល់រាវ<br>• ហាមចាក់ប្រេង រូបធាតុរំលាយ ឬប្រេងរំអិលទៅលើដី ស្ទឹង និងប្រព័ន្ធរំដោះទឹកនានាដែលមាននៅក្នុងតំបន់នោះ ។ | ធ្វើឱ្យកខ្វក់ដល់មជ្ឈដ្ឋានជុំវិញ | ទីវាល | សោភ័ណភាពមជ្ឈដ្ឋានជុំវិញ | - | - | - |

Draft

| ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ខួបនៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **ក្នុងពេលប្រតិបត្តិគំរោង – ការឈូសសំអាតព្រៃដើម្បីដាំដំណាំកៅស៊ូ (ត)** | | | | | | |
| • គ្មានវិធានការណាជាក់លាក់ដើម្បីកាត់បន្ថយផលប៉ះពាល់ ដែលកើតឡើងដោយសារការឈូសសម្អាតព្រៃទំហំ ៤.៣៨៥ ហិកតា នេះទេ។ តែក្រុមហ៊ុនបានរក្សាផ្ទៃដីទំហំ ៣២០ហិកតា (តំបន់ទ្រនាប់ប្រព័ន្ធផ្លូវទឹក) ដើម្បីធ្វើការអភិរក្ស។ តំបន់នេះនឹងដើរតួនាទីជារបៀងសត្វព្រៃយ៉ាងសំខាន់។<br>• តំបន់របៀងនេះ នឹងបង្កលក្ខណៈអោយសត្វព្រៃ ធ្វើបំលាស់ទីពីកន្លែងដែលទទួលរងការរំខានទៅកន្លែងផ្សេងទៀត។ មិនត្រឹមតែប៉ុណ្ណោះ អាចដើរតួនាទីជាទីតាំងយុទ្ធសាស្ត្រ សម្រាប់ថនិកសត្វតូចៗ មួយចំនួនលាក់ខ្លួន បានងាយស្រួលទៀតផង។<br>• គ្មានវិធានការមានប្រសិទ្ធិភាពជាក់លាក់ សម្រាប់ការពារពពួកឧរង្គសត្វមួយចំនួន (អាញី) ពីការកាប់ព្រលំឈើនោះទេ។ សត្វដែលរងគ្រោះដោយសារការកាប់ព្រលំឈើ ត្រូវយកទៅរក្សាទុកនៅការិយាល័យសត្វព្រៃ របស់រដ្ឋបាលព្រៃឈើខេត្ត។<br>• តំបន់ទ្រនាប់ប្រព័ន្ធផ្លូវទឹកត្រូវរក្សា និងការពារអោយបានត្រឹមត្រូវ ដើម្បីការពារ នឹងទប់ស្កាត់ការហូរច្រោះ និងការរក្សាបាននូវទីកន្លែងបត្តពូជរបស់ពពួកមច្ឆាជាតិ។ | បាត់បង់ទីជំរក និងប៉ះពាល់ដល់សត្វព្រៃ | ទីវាល | តំបន់ទ្រនាប់ ត្រូវបានរក្សាទុកត្រឹមត្រូវតាមផែនការបែងចែកការប្រើប្រាស់ដី | - | - | - |

| ការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់ | Parameter ដែលត្រូវត្រួតពិនិត្យ | ទីតាំង | ការវាស់ស្ទង់ | ខួបនៃការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **ក្នុងពេលប្រតិបត្តិគំរោង - ការរក្សានូវគុណភាពទឹក**<br>• ត្រូវលុបបំបាត់នូវរាល់សកម្មភាពទាំងឡាយណា ដែលធ្វើឱ្យប៉ះពាល់ដល់គុណភាពទឹក នៅក្នុងរយៈពេលនៃការអនុវត្តន៍គំរោង តាមរយៈការគ្រប់គ្រងអ្នកម៉ៅការនៅក្នុងពេលនៃគំរោង។ ការប្រើប្រាស់នូវគ្រឿងចក្រក៏ដូចជាការដែលឈូសឈើគរួចដែរ ដើម្បីកាត់បន្ថយនូវការបន្ថែមរូបធាតុកខ្វក់ ដូចជាការហូររបស់ដីរចេញពីទីតាំងគំនរឈើសំបូរទៅដោយរូបធាតុ ស៊ុលហ្វីត និងដីរ ដែលនឹងហូរធ្លាក់ទៅក្នុងប្រព័ន្ធស្ទឹង។<br>• ទាមទារឱ្យមាននូវប្រព័ន្ធមួយដែលមានប្រសិទ្ធិភាព សំរាប់គ្រប់គ្រងការហូរច្រោះខ្សាច់ នៅក្នុងពេលសាងសង់នៅក្នុងដំណើរការនៃការរៀបចំផែនការដូចជាការជីកកប់នឹងចាក់បំពេញដីឬមួយក៏ការ រៀបចំប្រព័ន្ធភ្លឺដើម្បីទប់ស្កាត់ការហូរច្រោះ និងបំណែករបស់ដី។ ក្រៅពីនេះត្រូវផ្អាកការងារនៅក្នុងរដូវវស្សា ព្រោះថាតំបន់មួយចំនួននឹងកើតមាននូវដំណុះរុក្ខជាតិតាមលក្ខណៈធម្មជាតិជាថ្មីវិញ។<br>• ចំពោះអណ្តូងទឹកនៅក្នុងទីស្នាក់ការស្នូល ត្រូវជីកនូវកន្លែងមួយឆ្ងាយពីកន្លែងដែលមានមនុស្សកកកុញ និងកន្លែងដែលគេប្រើប្រាស់តាមលទ្ធភាពដែលអាចធ្វើទៅបានជាពិសេសត្រូវ ឆ្ងាយពីលូទឹកស្អុយ បង្គន់ និងកន្លែងដែលគេបោះសម្រាមចោល។<br>• ការរៀបចំប្រព័ន្ធភ្លឺឬទំនប់បញ្ជៀសទឹក ចាំបាច់ត្រូវយកចិត្តទុកដាក់ធ្វើយ៉ាងណា ដើម្បីធានាថាមិនបង្ករការខូចខាត ដល់ប្រព័ន្ធអេកូឡូស៊ីឬក៏ផ្លាស់ប្តូរចរន្តទឹករបស់ប្រព័ន្ធស្ទឹង ឬអូរដោយសំណង់ទំនប់នេះ ដែលជាហេតុឧបសគ្គដល់ការឆ្លងកាត់របស់ត្រីឬសត្វទឹកផ្សេងៗទៀត។ | ការធ្វើឱ្យកខ្វក់ដល់ប្រភពទឹក | ទីវាល | គុណភាពទឹក មាន : pH; BOD; COD; DO; TSS; Total Coliform; | - | - | - |

Draft

១៨៨. ក្រុមហ៊ុន **បៀន ហៀក អ៊ិនវេសមេន** **BEAN HEACK INVESTMENT Co., Ltd.** មានផែនការអភិវឌ្ឍន៍ មូលដ្ឋាន ដូចបាន ជំរាបជូនខាងលើមានបញ្ជាក់លំអិតនៅក្នុងតារាង ៦-៤ ខាង ក្រោម ។

**តារាង ៦-៤: ផែនការចូលរួមអភិវឌ្ឍន៍សហគមន៍មូលដ្ឋានរបស់ក្រុមហ៊ុន បៀន ហៀក អ៊ិនវេសមេន**

| កម្មវិធី | សកម្មភាពដែលត្រូវអនុវត្ត | គំរោងផ្ដល់ជូនក្នុងមួយឆ្នាំ | | |
|---|---|---|---|---|
| | | ចំនួន | ឯកតា | សរុប(ដុល្លា) |
| ការអនុវត្តន៍ផែនការអភិវឌ្ឍន៍ | ផ្ដល់អណ្ដូងទឹកស្អាត (០១/០៥គ្រួសារ) | ១០ | ១.៥០០ | ១៥.០០០ |
| | ជួសជុល និងសាងសង់ផ្លូវលំជនបទក្នុងតំបន់គំរោង (ម) | ១.០០០ | ១០ | ១០.០០០ |
| | កសាង និងជួសជុលសាលារៀន (ក្នុងទីតាំងក្រុមហ៊ុន) | ០១ | ១២៥.០០០ | ១២៥.០០០ |
| | មណ្ឌលសុខភាព របស់ក្រុមហ៊ុន (០១ក្នុងតំបន់សម្បទាន) | ០១ | ៦០.០០០ | ៦០.០០០ |
| | សាងសង់ប្រព័ន្ធធារាសាស្ត្រ (ប្រាក់បរិច្ចាកសង្គម) | ដកប្រាក់ពីខ្ទង់ចំណាយផ្សេងៗ និងប្រាក់ធានារ៉ាប់រងសង្គម ២៦០.០០០ដុល្លា | | |
| **ការស្នើសុំឱ្យក្រុមហ៊ុនចូលរួមអភិវឌ្ឍន៍មូលដ្ឋានឃុំសាគ្រាម** | | | | |
| ផែនការស្នើសុំ | សុំឱ្យក្រុមហ៊ុនជួយសាងសង់ផ្លូវមួយខ្សែ ពីឃុំទៅកាន់ភូមិ នានា (ដូចជា ភូមិសាគ្រាមជើង ភូមិវាលថ្នល់ និងភូមិផ្សេងៗ) ។ | ០២ | ២.០០០ | ៤.០០០ |
| | ស្នើសុំអណ្ដូងទឹក | ០៧ | ១.៥០០ | ១០.៥០០ |
| | ស្នើសុំម៉ាស៊ីនភ្លើងដាក់សាលាឃុំ ០១គ្រឿង | ០១ | ១.២០០ | ១.២០០ |
| | សុំម៉ូតូសំរាប់បំរើការងារក្នុងឃុំ | ០១ | ១.២០០ | ១.២០០ |
| | សុំឱ្យក្រុមហ៊ុនផ្ដល់អាទិភាពការងារដល់អ្នកភូមិ | ប្រជាពលរដ្ឋក្នុងមូលដ្ឋានទទួលបានអាទិភាពការងារជាងអ្នកចំណូលស្រុក | | |
| | ជួយបង្កើតប៉ុស្ដិ៍សុខភាពឱ្យបានគ្រប់ភូមិ | អ្នកជំងឺទៅព្យាបាលក្នុងមណ្ឌលសុខភាពក្រុមហ៊ុន | | |

Draft